## តំបន់មេគង្គត្រូវការការផ្ទេរឆ្ពោះទៅរកថាមពលដែលមានយុត្តិធម៌  មិនមែនថាមពលតាមរយៈការសង់ទំនប់វារីអគ្គិសនីដែលមានលក្ខណៈបំផ្លាញនោះទេ

នៅថ្ងៃទី១១ ខែឧសភា គណៈកម្មការទន្លេមេគង្គ(MRC) បានប្រកាសថា គម្រោងទំនប់វារីអគ្គិសនី សាណាខាំ(Sanakham) នៅប្រទេសឡាវ នឹងត្រូវនៅក្រោម ដំណើរការនៃនិតិវិធីពិគ្រោះយោបល់ជាមុន របស់ គណៈកម្មការទន្លេមេគង្គ។[1] គម្រោងទំនប់សាណាខាំ គឺជាគម្រោងទំនប់ ទី៦ នៅលើដងទន្លេមេនៃទន្លេមេគង្គ ដែលត្រូវបានស្នើឡើង ដើម្បីធ្វើការពិគ្រោះយោបល់ជាមុន។

ទំនប់សាណាខាំដែលត្រូវបានស្នើឡើង មានតម្លៃថ្លៃ មិនចាំបាច់ និងមានលក្ខណៈប្រថុយប្រថាន- ហើយវាគួរតែត្រូវបានលុបចោល។ ទំនប់នេះ មានកម្លាំងផលិត ៦៨៤មេហ្គាវ៉ាត់ នឹងត្រូវចំណាយថវិកាអស់ជាង២ពាន់លានដុល្លា ដោយចំណាយពេល៨ឆ្នាំដើម្បីសាងសង់។ បើគិតជាមធ្យមភាគ ក្នុងរយៈពេល៨ឆ្នាំ ទំនប់សាណាខាំ អាចបន្ថែមថាមពលប្រមាណ៩០មេហ្គាវ៉ាត់ក្នុងមួយឆ្នាំ ដែលកំណើននេះមានលក្ខណៈអន់ថយ បើធៀបនឹងការតម្លើងនៃប្រភពថាមពលដែលប្រកបដោយនិរន្តរភាព ដែលកំពុងមានដំណើរការនៅក្នុងតំបន់។ ជាក់ស្តែង ក្នុងចន្លោះខែមេសា និងខែកក្កដា ឆ្នាំ២០១៩ ប្រទេស វៀតណាមបានបន្ថែម ថាមពលដើរដោយពន្លឺព្រះអាទិត្យប្រមាណ ៤៤០០មេហ្គាវ៉ាត់របស់ខ្លួន[2] ដែល បរិមាណនេះ គឺ៦ដងច្រើនជាងសមត្ថភាពផលិតរបស់ទំនប់វារីអគ្គិសនីសាណាខាំ ។

ជាមួយនឹងការវិវត្តន៍យ៉ាងឆាប់រហ័សនៃ បច្ចេកវិទ្យា និងការវិនិយោគនៅក្នុងវិស័យថាមពល គម្រោងវារីអគ្គិសនីធំៗដូចជាទំនប់សាណាខាំនេះ នឹងប្រឈមជាមួយហានិភ័យដ៏ធំធេង ពីព្រោះវាត្រូវចំណាយពេលច្រើនឆ្នាំក្នុងការសាងសង់ និងចំណាយថវិកាវិនិយោគច្រើនជាមុន ហើយវានឹងក្លាយជាធនធានខាតបង់។ ហានិភ័យផ្ទួបដែលបណ្តាលមកពីបម្រែបម្រួលអាកាសធាតុ និងទំនប់វារីអគ្គិសនីដែលមានស្រាប់នៅខ្សែទឹកខាងលើ កំពុងតែបង្កឱ្យមានការលំបាកក្នុងការប៉ាន់ស្មានពីលំហូរទឹក និងកំពស់ទឹក នឹងបង្កឱ្យមានផលប៉ះពាល់ទៅលើបរិមាណនៃអគ្គិសនីដែលផលិតដោយ ទំនប់សាណាខាំ និងទំនប់វារីអគ្គិសនីដទៃទៀតនៅលើដងទន្លេមេគង្គ។

ថាមពលអគ្គិសនីភាគច្រើនដែលផលិតតាមរយៈទំនប់សាណាខាំ ត្រូវបានគ្រោងនាំចេញទៅប្រទេសថៃ។ ទោះជាយ៉ាងណាក៏ដោយ ប្រទេសថៃមានការផ្គត់ផ្គង់អគ្គិសនីលើសលុបស្រាប់ទៅហើយ។ ភាពលើសលុប

---

[1] See MRC Media release, 11 May 2020, ‘Laos to undertake prior consultation for Sanakham hydropower project’

[2] See ‘Update Vietnam Power Sector’, presentation at the 26th Meeting of the Regional Power Trade Coordination Committee (RPTCC-26), Hanoi, November 2019

នេះកើនឡើងរឹតតែច្រើន ដោយសារតែឱនភាពសេដ្ឋកិច្ច និងការរីករាលដាលនៃជំងឺកូវីដ-១៩។ ការរាតត្បាតនៃជំងឺកូវីដ-១៩ បានគូសបញ្ជាក់ ពីសារៈសំខាន់នៃដីស្រែចំការ ព្រៃឈើ ទន្លេ ដីលិចទឹក និងធនធានផលផលតាមដងទន្លេមេគង្គ ដែលជាប្រព័ន្ធសុវត្ថិភាពរបស់ប្រជាជនក្នុងគ្រាមានវិបត្តិ។ ការបន្តលទ្ធភាពដល់ប្រជាជនក្នុងតំបន់ក្នុងការទទួលបានការប្រើប្រាស់ទន្លេ និងធនធានធម្មជាតិ មានសារៈសំខាន់ណាស់ ដើម្បីធានាបាននូវការធូរស្រាលពីជំងឺរាតត្បាត ប្រកបសមភាព និងសុខភាពល្អ។

ថ្វីបើទីតាំងនៃគម្រោងទំនប់វារីអគ្គិសនីសាណាខាំ ស្ថិតនៅលើដងទន្លេមេគង្គ និងក្នុងចម្ងាយប្រហែល២គីឡូម៉ែត្រពីព្រំដែនថៃ-ឡាវក៏ដោយ គេពុំឃើញមានការពិចារណាឱ្យបានហ្មត់ចត់លើផលប៉ះពាល់ឆ្លងដែនរបស់គម្រោងនេះ  នេះមិនគិតពីកិច្ចពិគ្រោះយោបល់ប្រកបដោយអត្ថន័យ លើផលប៉ះពាល់នេះផង។ ខ្លឹមសារភាគច្រើននៅក្នុងរបាយការណ៍វាយតំលៃហេតុ ប៉ះពាល់ឆ្លងដែនផ្នែកបរិស្ថាន និងសង្គម និងការវាយតម្លៃហេតុផលប៉ះពាល់ជាបណ្តុំ (TBESIA/CIA)[3] គឺជា**ខ្លឹមសារចាស់ និង ចម្លងចេញ**ពីខ្លឹមសារនៃការវាយតម្លៃ TBESIA/CIA របស់គម្រោងទំនប់ប៉ាក់ឡាយ។ ឧទាហរណ៍ ជំពូកស្តីពី ការចូលរួមជាសាធារណៈ សេចក្តីសន្និដ្ឋាន និង អនុសាសន៍គឺវាមានខ្លឹមសារដូចទាំងស្រុងទៅនឹងខ្លឹមសារនៃការវាយតម្លៃTBESIA/CIA របស់គម្រោងប៉ាក់ឡាយ។ អ្វីដែល ខុសគ្នា គឺគ្រាន់តែឈ្មោះគម្រោងប៉ុណ្ណោះ។ ការវាយតម្លៃ TBESIA/CIA  ស្ទើរតែមិនបានពិចារណាពីការសិក្សានានាកន្លងមក អំពីទន្លេមេគង្គ និងផលប៉ះពាល់នៃគម្រោងថាមពលវារីអគ្គិសនីនានា ដែលបាន បោះពុម្ពផ្សាយក្នុងអំឡុងពេល១០ឆ្នាំចុងក្រោយឡើយ។[4] នេះគឺជាករណីដែល**មិនអាចទទួលយកបានឡើយ** ជាពិសេសសម្រាប់គម្រោងដែលមានផលប៉ះពាល់ឆ្លងដែនដ៏ធំធេងទៅលើទន្លេដែលប្រជាជនរាប់លាននាក់កំពុងពឹងអាស្រ័យ។

**ជាជាងការបន្តធ្វើការៈពិគ្រោះយោបល់ៈដែលមានចន្លោះប្រហោងនេះ  យើងសូមអំពាវនាវឱ្យលុបចោលផែនការកសាងទំនប់វារីអគ្គិសនីសាណាខាំ និងទំនប់វារីអគ្គិសនីផ្សេងទៀតនៅលើដងទន្លេមេគង្គ។ សម្ព័ន្ធសង្គ្រោះទន្លេមេគង្គ ជំរុញឱ្យរដ្ឋាភិបាលនានានៅតំបន់មេគង្គក្រោម និងគណៈកម្មការទន្លេមេគង្គ អនុវត្តនូវចំនុចខាងក្រោម៖**

- **ដោះស្រាយបញ្ហា ចំបងនានា ពាក់ព័ន្ធនឹងផលប៉ះពាល់របស់ទំនប់វារីអគ្គិសនីដែលមានស្រាប់**
- **ធ្វើការវាយតម្លៃ ដោយមានការចូលរួម និងដោយទូលំទូលាយ ទៅលើជម្រើសថាមពលដទៃទៀត និងផ្តល់អាទិភាពដល់ជំហាន  ការផ្ទេរឆ្ពោះទៅរកថាមពលដែលមានយុត្តិធម៌ ដែលអាចរក្សាបាននូវប្រព័ន្ធអេកូឡូស៊ីសំខាន់ៗរបស់ទន្លេមេគង្គ និងឆ្លើយតប ព្រមទាំងការពារតម្រូវការរបស់សហគមន៍នៅក្នុងតំបន់**
- **ដោះស្រាយបញ្ហាចំបងៗដែលនៅសេសសល់ ស្តីពីនិតិវិធីនៃដំណើរការពិគ្រោះយោបល់ជាមុន។**

---

[3] See Sankaham Hydropower Project, [‘Transboundary Environmental and Social Impact Assessment and Cumulative Impact Assessment’](), October 2018

[4] These include but are not limited to:  MRC Technical review reports of mainstream dams submitted to Prior Consultation; the findings and recommendations of the 2010 Strategic Environmental Assessment of Hydropower on the Mekong Mainstream; the findings and recommendations of the MRC Council Study etc, which are available through the MRC website

## ដោះស្រាយបញ្ហាចំបងៗពាក់ព័ន្ធនឹងផលប៉ះពាល់របស់ទំនប់ដែលមានស្រាប់

ទំនប់វារីអគ្គិសនីដែលបានសាងសង់រួចនៅទន្លេឡានឆាង-មេគង្គ និងដៃទន្លេនេះ កំពុងបង្កផលប៉ះពាល់ជាបណ្តុំយ៉ាងច្រើនដល់បរិស្ថាន និងសហគមន៍ដែលរស់នៅតាមដងទន្លេ និងប៉ះពាល់ពាល់ឆ្លងដែនថែមទៀត។ ប៉ុន្តែបញ្ហាដែលកំពុងមានស្រាប់ទាំងនេះ រួមទាំងផលប៉ះពាល់ឆ្លងដែន ផលប៉ះពាល់លើជីវភាព ដីធ្លី និងជីវិតនានារបស់មនុស្ស ភាគច្រើននៅមិនទាន់បានដោះស្រាយនៅឡើយ។[5] រដ្ឋាភិបាលឡាវមិនបានអនុវត្តតាមកិច្ចប្តេជ្ញារបស់ខ្លួន ក្នុងការពិចារណាឡើងវិញលើយុទ្ធសាស្ត្រវារីអគ្គិសនីបន្ទាប់ពីមានការបាក់ទំនប់វារីអគ្គិសនីសេពានសេណាមណយ (Xe-Pian-Xe Namnoy dam)។

ជំនួសឲ្យការបន្ត ការសាងសង់ទំនប់វារីអគ្គិសនីបន្ថែម ក្រោមហេតុផល"ទំនប់វារីអគ្គិសនីប្រកបដោយនិរន្តរភាព" និងយន្តការកាត់បន្ថយហានិភ័យដែលពុំមានភស្តុតាងណាបង្ហាញថាវាពិតជាមានប្រសិទ្ធភាពនៅឡើយ រដ្ឋាភិបាល អ្នកអភិវឌ្ឍន៍ និងអ្នកផ្តល់ហិរញ្ញប្បទានត្រូវតែផ្តល់អាទិភាពលើការដោះស្រាយបញ្ហាដែលបង្កដោយទំនប់វារីអគ្គិសនីដែលមានស្រាប់ ដើម្បីលើកកម្ពស់ជីវភាព និងសុខុមាលភាពរបស់សហគមន៍ដែលបានរងផលប៉ះពាល់ពីទំនប់វារីអគ្គិសនីទាំងនោះ។

## ធ្វើការវាយតម្លៃ ដោយមានការចូលរួម និងដោយទូលំទូលាយទៅលើជម្រើសថាមពលដទៃទៀត និងផ្តល់អាទិភាពដល់ជំហានដែលផ្ទេរឆ្ពោះទៅរកថាមពលដែលមានយុត្តិធម៌

មិនចាំបាច់សង់ទំនប់វារីអគ្គិសនីនៅលើដងទន្លេមេគង្គដើម្បីបំពេញតម្រូវការថាមពល និងតម្រូវការទឹកក្នុងតំបន់នោះទេ។ ប្រទេសថៃដែលត្រូវបានកំណត់ជាភាគីទិញថាមពលអគ្គិសនីដ៏ធំ ដែលទាញចេញពីទំនប់វារីអគ្គិសនីនៅតាមតួមេនៃទន្លេមេគង្គ ឥឡូវនេះ កំពុងមានថាមពលបម្រុងលើសលុប។ កាលពីខែមេសា ក្រសួងថាមពលថៃបានបញ្ជាក់ថា ថាមពលបម្រុងនៅឆ្នាំ២០២០មានដល់ទៅ៤០%ដែលស្មើនឹងប្រមាណ១៨,០០០មេហ្គាវ៉ាត់។[6] បរិមាណបម្រុងនេះ លើសពីកំលាំងផលិតសរុបនៃការរួមបញ្ចូលគ្នារបស់ទំនប់វារីអគ្គិសនីដែលនៅលើតួមេនៃទន្លេមេគង្គក្រោមទាំងអស់ទៅទៀត។ នៅខែមីនាឆ្នាំ២០២០ រដ្ឋាភិបាលកម្ពុជាបានប្រកាសថា ខ្លួននឹងផ្អាកគម្រោងទំនប់វារីអគ្គិសនីសំបូរ និងស្ទឹងត្រែង យ៉ាងតិចណាស់រហូតដល់រយៈពេល១០ឆ្នាំទៀត។[7]

**ឥឡូវនេះគឺជាពេលវេលាដែលត្រូវលុបចោលទំនប់វារីអគ្គិសនីនៅលើតួមេនៃទន្លេមេគង្គជាអចិន្ត្រៃយ៍ និងផ្តល់អាទិភាពទៅលើជម្រើសថាមពលប្រកបដោយនិរន្តរភាព និងសមធម៌ ដែលគោរពសិទ្ធិសហគមន៍។** តំបន់មេគង្គមានសក្តានុពលថាមពលយ៉ាងធំធេងក្នុងការផលិតថាមពលដែលមាននិរន្តរភាព ដែលមិនចាំបាច់ទាញចេញពីទំនប់វារីអគ្គិសនី ហើយជាតំបន់ដែលមានសក្តានុពលក្នុងការបង្កើនប្រសិទ្ធភាពថាមពលខ្ពស់ ។ កត្តានេះ រួមជាមួយនឹងភាពជឿនលឿនយ៉ាងឆាប់រហ័សលើផ្នែកបច្ចេកវិទ្យាថាមពល និងការធ្លាក់ចុះនៃតម្លៃនៃបច្ចេកវិទ្យាក្នុងការផលិត បញ្ជូន និងរក្សាទុកថាមពលប្រកបដោយនិរន្តរភាព ដែលអាចនាំឱ្យយើងសំរេចបាន

---

[5] E.g. See: Lao dam disaster: UN rights experts call for justice two years on (29 April 2020)

[6] Thailand's installed capacity is approx. 45,000MW; 40% is 18,000MW

[7] https://www.theguardian.com/world/2020/mar/20/cambodia-scraps-plans-for-mekong-hydropower-dams

នូវការផ្គត់ផ្គង់ថាមពល និងធានាសន្តិសុខសម្រាប់ប្រជាជន និងសេដ្ឋកិច្ចក្នុងតំបន់ ដោយមិនបំផ្លាញទន្លេ និងធនធានធម្មជាតិ។ លើសពីនេះទៅទៀត វិធានការប្រសិទ្ធភាពថាមពល និងថាមពលកកើតឡើងវិញដោយមិនប្រើវារីអគ្គិសនី អាចអោយប្រើប្រាស់កាន់តែទូលំទូលាយ ឆាប់រហ័យ និងក្នុងតម្លៃទាបជាងគម្រោងវារីអគ្គិសនីខ្នាតធំ។

ជំនួសឱ្យការចំណាយថវិកាលើការពិគ្រោះយោបល់ដែលមានចន្លោះប្រហោង គេគួរចំណាយធនធានសម្រាប់វាយតម្លៃជម្រើសថាមពលនានា ដោយមានការចូលរួម និងភាពទូលំទូលាយ ដើម្បីស្វែងរកប្រភពថាមពលដែលអាចជួយផ្នែកសេដ្ឋកិច្ច និងអនាគតថាមពលប្រកបដោយនិរន្តរភាព និងសមធម៌។ ការវាយតម្លៃបែបនេះគួរតែផ្តល់អាទិភាពដល់ការអភិវឌ្ឍផ្នែកថាមពលប្រកបដោយយុត្តិធម៌ ដែលមានន័យថា ធានាបាននូវការផ្លាស់ប្តូរ ទៅលើការកសាង ការផលិត ការចែកចាយ និងការប្រើប្រាស់ថាមពល ដោយមិនខ្ជះខ្ជាយធនធាន និងការពារដល់សិទ្ធិមនុស្ស និងបរិស្ថាន។

## ដោះស្រាយបញ្ហាចំបងៗដែលនៅសេសសល់ ស្តីពីនិតិវិធីនៃ កិច្ចពិគ្រោះយោបល់ជាមុន

សម្ព័ន្ធសង្គ្រោះទន្លេមេគង្គ បានលើកឡើងជាកង្វល់ម្តងហើយម្តងទៀត និងបានចង្អុលបង្ហាញអំពីការខ្វះចន្លោះនៅក្នុងដំណើរការពិគ្រោះយោបល់ជាមុន។[8] ប៉ុន្តែក្តីបារម្ភ និងសំណូមពររបស់សង្គមស៊ីវិល រដ្ឋាភិបាលដែលជាសមាជិកគណៈកម្មការទន្លេមេគង្គ និងដៃគូអភិវឌ្ឍន៍ រួមទាំងការអំពាវនាវសុំឱ្យមានការសិក្សាស្រាវជ្រាវ និងព័ត៌មានបន្ថែម ភាគច្រើន នៅតែមិនទាន់ត្រូវបានដោះស្រាយនៅឡើយ។

ក្រៅពីនេះ នៅមិនទាន់មាននីតិវិធីដើម្បីធានាឱ្យមាននូវគុណភាពព័ត៌មាន ដែលត្រូវដាក់ជូនសម្រាប់ដំណើរការពិគ្រោះយោបល់ជាមុននៅឡើយ។ ខ្លឹមសារមួយផ្នែកធំនៃការវាយតម្លៃផលប៉ះពាល់ TBESIA/CIA របស់ទំនប់សាណាខាំ ជាការចម្លងអត្ថន័យខ្លឹមសារចេញពីការវាយតម្លៃរបស់ទំនប់ប៉ាក់ឡាយ ដែល គណៈកម្មការទន្លេ មេគង្គបានរកឃើញ និងបញ្ជាក់ថា វាគឺជាការវាយតម្លៃ "**បឋម និងភាគច្រើនចម្លងពីគម្រោងទំនប់ប៉ាក់បេង**" [9]។ ករណីនេះបង្ហាញថា សំណើរនានាកន្លងមកដែលបានស្នើឱ្យមានការសិក្សាឱ្យបានទូលំទូលាយ រួមទាំងទៅលើទិន្នន័យមូលដ្ឋាន និងការសិក្សាហេតុផលប៉ះពាល់ មិនត្រូវបានគេអនុវត្តតាម និងមិនបានដាក់បញ្ចូលសំណើរទាំងនោះទៅក្នុងការវាយតម្លៃផលប៉ះពាល់នៃគម្រោងទំនប់វារីអគ្គិសនីបន្តបន្ទាប់ដទៃទៀត។ ដោយឃើញមានការចម្លងអត្ថន័យខ្លឹមសារចេញពីការវាយតម្លៃគម្រោងមុន ម្តងហើយម្តងទៀត ហេតុដូចនេះ ក្រុមហ៊ុនពិគ្រោះយោបល់ជាតិ [National Consulting Group (NCG)] និងទីប្រឹក្សាពិគ្រោះយោបល់ ដែលបានប្រលូកពាក់ព័ន្ធនឹងការវាយតម្លៃហេតុផលប៉ះពាល់ TBESIA/CIA របស់គម្រោងប៉ាក់បេង ប៉ាក់ឡាយ និងសាណាខាំ គួរត្រូវបានហាមឃាត់មិនឱ្យចូលរួមនៅក្នុងការវាយតម្លៃហេតុផលប៉ះពាល់ផ្សេងៗទៀតទេ។

---

[8] E.g see Save the Mekong coalition statements issued in: May 2017 (Pak Beng dam); July and August 2018 (Pak Lay); and October 2019 (Luang Prabang dam)

[9] Mekong River Commission (2019: 44), Comprehensive Summary: Technical Review Report – Prior Consultation for the Proposed Pak Lay Hydropower Project.

យើងគូសបញ្ជាក់ជាថ្មី ពីគោលជំហររបស់ពួកយើងដែលមាននៅក្នុងសេចក្តីថ្លែងការណ៍ចេញកាលពីខែតុលា ឆ្នាំ២០១៩ ថា "...បើគ្មានកំណែទម្រង់ប្រកបដោយខ្លឹមសារទេ... នេះបង្ហាញថា ដំណើរការពិគ្រោះយោបល់ជាមុននេះនៅតែមានស្ថានភាពដដែលៗ ដែលមានកំណែទំរង់តិចតួចណាស់ ... ដែលនេះមិនមានភាពខុសគ្នាពីបទពិសោធន៍កន្លងមកនោះទេ ហើយដែលវាក៏នឹងមិនអាចធានាបាននូវបទដ្ឋានតម្លាភាព និងគណនេយ្យភាព សូម្បីត្រឹមកំរិតដ៏ទាបបំផុតក៏មិនអាចធានាបាន ហេតុដូចនេះ មិនចាំបាច់និយាយទៅដល់ការចូលរួមប្រកបដោយអត្ថន័យពីសំណាក់សហគមន៍ដែលរងផលប៉ះពាល់ សង្គមស៊ីវិល និងសាធារណជនទូទៅឡើយ។"[10]

**សម្ព័ន្ធសង្គ្រោះទន្លេមេគង្គ**
ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២០

[10] Save the Mekong Coalition Calls for the Cancelation of the Luang Prabang Dam, 9 October 2019